**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ១១៩៤៦ អពដ

ថ្ងៃអង្គារ ១០កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៨

# សេចក្តីណែនាំ
# ស្តីពី
# វិធានការប្រាក់ចំពោះបុគ្គលទាក់ទិន

អនុលោមតាមប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ស្តីពីវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន និងយោងតាមសេចក្តីណែនាំលេខ១១៥១ អពដ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវចំពោះប្រតិបត្តិការខ្ចីប្រាក់ក្នុងចំណោមបុគ្គលទាក់ទិន អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដូចតទៅ÷

១. សហគ្រាសដែលមានប្រតិបត្តិការខ្ចីប្រាក់ក្នុងចំណោមបុគ្គលទាក់ទិន ត្រូវកំណត់ការប្រាក់ពីការខ្ចីប្រាក់នោះឱ្យស្របតាមគោលការណ៍ជំហោងដៃ (Arm’s Length Principle) ដូចមានចែងក្នុងប្រកាសស្តីពីវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន។

២. សហគ្រាសមិនតម្រូវឱ្យដាក់ឯកសារខ្ចីប្រាក់មករដ្ឋបាលសារពើពន្ធដើម្បីស្នើសុំការអនុម័តយល់ព្រមនោះទេ ប៉ុន្តែអ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងរក្សាទុកនូវឯកសារផ្សេងៗទាក់ទិននឹងកម្ចីនោះ និងត្រូវផ្តល់ជូនតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងប្រការ១៨ នៃប្រកាសស្តីពីវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន។

សេចក្តីណែនាំនេះអនុវត្តចំពោះតែប្រតិបត្តិការក្នុងចំណោមបុគ្គលទាក់ទិនប៉ុណ្ណោះ ដោយឡែកចំពោះប្រតិបត្តិការខ្ចីប្រាក់ធ្វើឡើងដោយបុគ្គលមិនជាប់ទាក់ទិន ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ១១៥១ អពដ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស។

គ្រប់អង្គភាពពន្ធដារ និងសហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**ចម្លងជូន÷**
- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  “ដើម្បីជូនជ្រាប”
- គ្រប់អង្គភាពពន្ធដារ “ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ